ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៥ សរណន

# សេចក្តីណែនាំរួម
## ស្តីពី
## ការអនុវត្តន៍អនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦

ក្នុងគោលបំណងរួមជំរុញការងាររបស់គណៈកម្មការសុរិយោដីគ្រប់ថ្នាក់សំដៅកាត់បន្ថយ និងដោះស្រាយបញ្ហាប់ទំនាស់ដីធ្លី ពិសេសនៅថ្នាក់ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការណែនាំដល់អាជ្ញាធរដែនដីខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ក្នុងការអនុវត្តអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ ដូចខាងក្រោម :

១-អភិបាលស្រុក ខណ្ឌក្នុងមុខតំណែង ត្រូវទទួលភារកិច្ចជាប្រធានគណៈកម្មការសុរិយោដី ស្រុក ខណ្ឌ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។ ចំពោះស្រុក ខណ្ឌដែលពុំទាន់តែងតាំងអភិបាល អភិបាលរងដែលទទួលបន្ទុកដឹកនាំការងាររួម មានភារកិច្ចដឹកនាំគណៈកម្មការសុរិយោដីស្រុក ខណ្ឌនោះ ។ អភិបាលស្រុក ខណ្ឌដែលជាប់បេសកកម្មក្រៅប្រទេស ឬអវត្តមានរយៈពេលយូរ ត្រូវផ្ទេរសិទ្ធិជូនអភិបាលរង ០១ រូប ទទួលបន្ទុកដឹកនាំបន្តគណៈកម្មការសុរិយោដី ស្រុក ខណ្ឌនោះ ។ អភិបាលរងស្រុក ខណ្ឌដែលបានទទួលសិទ្ធិដឹកនាំការងារនេះ ត្រូវរាយការណ៍អំពីលទ្ធផលការងារជូនប្រធានគណៈកម្មការសុរិយោដីស្រុក ខណ្ឌ ពេលមានវត្តមាននៅអង្គភាពវិញ ។

២-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌក្នុងមុខតំណែង ត្រូវទទួលភារកិច្ចជាអនុប្រធានគណៈកម្មការសុរិយោដី ស្រុក ខណ្ឌ ។ ចំពោះការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដែលពុំទាន់មានប្រធានការិយាល័យ ប្រធានគណៈកម្មការសុរិយោដីស្រុក ខណ្ឌត្រូវលើកសំណើជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងការតែងតាំងបណ្តោះអាសន្នអនុប្រធានគណៈកម្មការសុរិយោដីស្រុក ខណ្ឌនោះ ។

/២

៣- គណៈកម្មការសុរិយោដីស្រុក ខណ្ឌ ត្រូវសិក្សាស្រាវជ្រាវស្វែងយល់ច្បាប់ និងបទដ្ឋានគតិយុត្ត នានាក្នុងការអនុវត្តន៍អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ប្រកាសលេខ១១២ ដនស.ប្រក.ចុះថ្ងៃទី ២១ខែ សីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំនីតិវិធីរបស់គណៈកម្មការសុរិយោដី និងប្រកាសរួមលេខ ០២ ប្រករ/០៣ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធ នឹងរឿង វិវាទដីធ្លី ។

អាជ្ញាធរដែនដី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តសេចក្តី ណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
ស ខេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ
អ៊ឹម ឈុនលឹម

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង
-ទីស្តីគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
-គ្រប់មន្ទីរ ដនសស.ខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ